ប្រព័ន្ធការការពារ និងការតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា

# ផែនការថែទាំសុខភាពដែលចាត់ចែងដោយ Medi-Cal និង សេវាកម្មថែទាំសុខភាពចិត្ត

*ការបោះពុម្ពផ្សាយប្រចាំខែមករា ឆ្នាំ 2018 #5609.06 - Cambodian*

## ផែនការថែទាំសុខភាពដែលចាត់ចែងដោយ Medi-Cal និង សេវាកម្មថែទាំសុខភាពចិត្ត

សេវាកម្មថែទាំសុខភាពផ្លូវចិត្តមួយចំនួន មានផ្តល់ជូនដោយគិតថ្លៃទៅតាមសេវាកម្ម Medi-Cal[1] របស់អ្នកផ្តល់សេវាកម្ម ឬតាមផែនការថែទាំសុខភាព ដែលចាត់ចែងដោយ Medi-Cal ខណៈពេលដែលសេវាកម្មផ្សេងទៀត គឺមានផ្តល់ជូនតែតាមរយៈផែនការថែទាំសុខភាពផ្លូវចិត្ត របស់ខោនធីក្រោមការបោះបង់សេវាកម្មឯកទេសថែទាំសុខភាពផ្លូវចិត្ត[2] តែប៉ុណ្ណោះ ។ ឧទាហរណ៍នៃសេវាកម្មឯកទេសថែទាំសុខភាពផ្លូវចិត្ត មានដូចជាការព្យាបាលហ្មត់ចត់នៅពេលថ្ងៃ ការស្តានីតិសម្បទានៅពេលថ្ងៃ

---

[1] បើអ្នកស្ថិតក្រោមការបង់ថ្លៃតាមការផ្តល់សេវាកម្មរបស់ Medi-Cal អ្នកអាចទៅទទួលសេវាកម្មពីអ្នកផ្តល់សេវាកម្មណាមួយក៏បាន ឲ្យតែគេទទួលថ្លៃសេវាកម្មតាមរយៈ Medi-Cal ។ វាក៏មានន័យផងដែរថា អ្នកមិនបានចុះឈ្មោះចូលក្នុងផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែងទេ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[2] ក្រមសុខុមាលភាព និងមន្ទីរព្យាបាល (Welfare & Institutions Code § 14189)
"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

និងសេវាកម្មការព្យាបាលមនុស្សពេញវ័យនៅតាមកន្លែងស្នាក់នៅ[3] ។ សម្រាប់ព័ត៌មានបន្ថែម ស្ដីអំពីសេវាកម្មឯកទេសថែទាំសុខភាពផ្លូវចិត្ត សូមអានឯកសារបោះពុម្ពផ្សាយស្ដីអំពី "ការទទួលបានសេវាកម្មឯកទេសថែទាំសុខភាពផ្លូវចិត្តសម្រាប់អ្នកជម្ងឺផ្លូវចិត្ត Medi-Cal ដែលមិនស្នាក់នៅមន្ទីរព្យាបាល (Getting Medi-Cal Outpatient Specialty Mental Health Services)" 508401[4] ។

ឯកសារបោះពុម្ពផ្សាយនេះ ផ្ដោតលើសេវាកម្មថែទាំសុខភាពចិត្តដែលអាចរកបានតាមរយៈផែនការថែទាំ Medi-Cal ដែលមានការចាត់ចែង ។

## តើអ្វីជាផែនការថែទាំសុខភាពដែលមានការចាត់ចែង?

ផែនការថែទាំសុខភាពដែលមានការចាត់ចែង គឺជាបណ្ដាញអ្នកផ្ដល់ការថែទាំសុខភាព ដោយបូករួមទាំងមន្ទីរពេទ្យ គ្រូពេទ្យ ។ល។ ដែលផ្ដល់សេវាកម្មដល់សមាជិករបស់ខ្លួន ។ អ្នកត្រូវតែប្រើប្រាស់សេវាកម្មរបស់អ្នកផ្ដល់សេវាកម្ម និងទីកន្លែងរបស់ពួកគេដែលនៅក្នុងបណ្ដាញដើម្បីទទួលបានសេវាកម្ម លើកលែងតែករណីគ្រាអាសន្នតែប៉ុណ្ណោះ ។ អ្នកត្រូវជ្រើសរើសគ្រូពេទ្យព្យាបាលបឋម (PCP, Primary Care Physician) ដែលនឹងសម្របសម្រួលការថែទាំសុខភាពរបស់អ្នក និងបញ្ជូនអ្នកទៅកាន់គ្រូពេទ្យឯកទេស បើចាំបាច់ ។ ត្រង់នេះគឺមានភាពខុសគ្នាពី សេវាកម្មបង់ថ្លៃ ដែលអ្នកអាចទៅរកអ្នកផ្ដល់សេវាកម្មណាម្នាក់ក៏បាន ឲ្យតែគេទទួលយកការបង់ប្រាក់តាមកម្មវិធី Medi-Cal ។

---

[3] 9 C.C.R. 1810.247 "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[4]សូមអានផងដែរ ៖ ការបញ្ជាក់អំពីការទទួលខុសត្រូវចំពោះផែនការសុខភាពចិត្ត សម្រាប់ការផ្ដល់សេវាកម្មឯកទេសផ្នែកសុខភាពផ្លូវចិត្តចំពោះអតិថិជនដែលបានចុះឈ្មោះក្នុងផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែង "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

ផែនការថែទាំសុខភាពដែលមានការចាត់ចែង អាចជាផែនការឯកជន ឬផែនការសាធារណៈ ។ ផែនការថែទាំសុខភាពដែលមាន ការចាត់ចែងបែបសាធារណៈ មានដូចជាកម្មវិធី Medi-Cal និង Medicare ។ ការបោះពុម្ពផ្សាយនេះ នឹងផ្តោតលើផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែង ។

សម្រាប់ព័ត៌មានបន្ថែមស្តីអំពីផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែង សូមអាន "ផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែង។ តើផែនការទាំងនោះជាអ្វី?" តើខ្ញុំត្រូវដឹងអ្វីខ្លះអំពីផែនការនេះ? តើសេវាកម្ម ថែទាំសុខភាពផ្លូវចិត្តអ្វីខ្លះ ដែលផែនការថែទាំ Medi-Cal ដែលមានការចាត់ចែង ត្រូវ ផ្តល់ជូន?

មុនឆ្នាំ 2014 អតិថិជនរបស់ Medi-Cal ដែលស្ថិតក្នុងគម្រោងថែទាំសុខភាពដែលមានការចាត់ចែង បានទទួលសេវាកម្មថែទាំសុខភាព ក្នុងរង្វង់កិច្ចប្រតិបត្តិ PCP របស់ពួកគេ ហើយត្រូវបានបញ្ជូនទៅកាន់អ្នកផ្តល់សេវាកម្ម Medi-Cal ដែលទទួលថ្លៃតាមការផ្តល់សេវាកម្ម ឬផែនការថែទាំសុខភាពផ្លូវចិត្តរបស់ខោនធីសម្រាប់សេវាកម្មឯកទេសផ្នែកថែទាំសុខភាព ។ ចាប់តាំងពីថ្ងៃទី 1 ខែមករា ឆ្នាំ 2014 មក ផែនការថែទាំសុខភាពដែលមានការចាត់ចែង បានក្លាយជាអ្នកទទួលខុសត្រូវចំពោះការផ្តល់សេវាកម្មជាក់លាក់ផ្នែកថែទាំសុខភាពផ្លូវចិត្តដល់អ្នកបុគ្គលដែលមានពិការភាពផ្លូវចិត្ត ឬជម្ងឺផ្លូវអារម្មណ៍ ឬបញ្ហាអាកប្បកិរិយាពីកម្រិតស្រាលទៅមធ្យម ដែលបណ្តាលពីបញ្ហាសុខភាពចិត្ត ដូចមានរៀបរាប់ក្នុងសៀវភៅស្តីអំពីរោគវិនិច្ឆ័យ និងស្ថិតិនៃជម្ងឺផ្លូវចិត្ត (DSM, Diagnostic and Statistical Manual of mental Disorders) បើទោះបីជាពេលខ្លះសេវាកម្មទាំងអស់នោះ ស្ថិតនៅក្រៅកម្រិតប្រតិបត្តិរបស់ PCP ក៏ដោយចុះ ។

ក្រសួងសេវាកម្មថែទាំសុខភាពរដ្ឋកាលីហ្វ័រនីញ៉ា (DHCS, California Department of Health Care Services) បានចេញរាល់លិខិតអំពីផែនការថែទាំសុខភាពទាំងអស់ (APL, All Plan Letter) 17-018. លិខិត APL រៀបរាប់អំពីសេវាកម្មដែលមានសម្រាប់អតិថិជន Medi-Cal ដែលស្ថិតនៅក្នុងផែនការថែទាំសុខភាពដែលមានការចាត់ចែង និងការទទួលខុសត្រូវរបស់ផែនការថែទាំសុខភាពដែលមានការចាត់ចែង សម្រាប់ការសម្របសម្រួលសេវាកម្មសុខភាពផ្លូវចិត្តជាមួយនឹងផែនការថែទាំសុខភាពផ្លូវចិត្តរបស់ខោនធី ។

សេវាកម្មថែទាំអ្នកជម្ងឺផ្លូវចិត្តដែលមិនសម្រាកពេទ្យ ដែលមានការចាត់ចែង ត្រូវផ្តល់ ៖

- ការវាយតម្លៃ និងការព្យាបាលសុខភាពផ្លូវចិត្តជាលក្ខណៈបុគ្គល និងជាក្រុម (ការព្យាបាលផ្លូវចិត្តដោយមិនប្រើថ្នាំ) ៖
- សេវាកម្មសម្រាប់អ្នកជម្ងឺមិនសម្រាកពេទ្យ ដើម្បីត្រួតពិនិត្យការព្យាបាលដោយប្រើថ្នាំ
- មន្ទីរពិសោធន៍អ្នកជម្ងឺមិនសម្រាកពេទ្យ ថ្នាំ (មានថ្នាំដែលមិនរាប់បញ្ចូល) គ្រឿងផ្គត់ផ្គង់ និងថ្នាំបន្ថែម
- ការពិគ្រោះផ្នែកជម្ងឺវិកលចរិក
- ការធ្វើតេស្តជម្ងឺវិកលចរិក ដើម្បីវាយតម្លៃសុខភាពផ្លូវចិត្ត condition.[5]

ស្ថានភាព ដែលកំណត់ឃើញថាជាបញ្ហារបស់សាច់ញាតិ ដូចជា ការពិគ្រោះយោបល់ដល់ប្តីប្រពន្ធ ឬគ្រួសារ មិនត្រូវបានស្ថិតក្រោមការធានារ៉ាប់រងសុខភាពទេ ។

**តើចំនួនទឹកប្រាក់ដែលខ្ញុំអាចទទួលបានចំពោះថ្លៃព្យាបាលរបស់ផែនការថែទាំសុខភាពដែលមានការចាត់ចែង មានដែនកំណត់ដែរឬទេ?**

ទេ មិនមានដែនកំណត់ទេ ដរាបណាថ្លៃចំណាយទាំងនោះមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ ។

---

[5] APL 17-018 p. 6; Welf. & Inst. Code 14132.03 "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

## តើអ្វីជាបទដ្ឋាននៃភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ?

មានបទដ្ឋានខុសៗគ្នានៃភាពចាំបាច់ផ្នែកវេជ្ជ ។ សម្រាប់កុមារ និងមនុស្សនៅក្នុងវ័យក្មេងដែលមានអាយុក្រោម 21 ឆ្នាំ ផែនការថែទាំសុខភាពដែលមានការចាត់ចែង ត្រូវផ្តល់សេវាកម្មដែលចាំបាច់ដើម្បីកែតម្រូវ ឬធ្វើឲ្យប្រសើរឡើងនូវ ជម្ងឺ ឬស្ថានភាពរបស់របស់កុមារ[6] ។

សម្រាប់មនុស្សមានអាយុ 21 ឆ្នាំ និងចាស់ជាងនេះ ផែនការថែទាំសុខភាពដែលមានការចាត់ចែង ត្រូវគ្របដណ្តប់ចំពោះសេវាកម្មដែលមានហេតុផលសមរម្យ និងភាពចាំបាច់ដើម្បីការពារជីវិត បង្ការកុំឲ្យមានជម្ងឺធ្ងន់ធ្ងរ ឬដែលបង្កឲ្យមានពិការភាពធ្ងន់ធ្ងរ ឬដើម្បីកាត់បន្ថយការឈឺចុកចាប់ធ្ងន់ធ្ងរតាមរយៈការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជម្ងឺ ការឈឺចាប់ ឬរបួសស្នាម[7] ។

## នរណាជាអ្នកផ្តល់សេវាកម្មទាំងអស់នេះ?

អ្នកចិត្តសាស្ត្រ ពេទ្យវិកលចរិក បុគ្គលិកសង្គមកិច្ចខាងពិនិត្យនិងព្យាបាលអ្នកជម្ងឺដែលមានអាជ្ញាប័ណ្ណ និងអ្នកប្រឹក្សាបញ្ហាចំណងអាពាហ៍ពិពាហ៍ និងគ្រួសារ ។ បុគ្គលិកសង្គមកិច្ចខាងពិនិត្យនិងព្យាបាលអ្នកជម្ងឺ ជំនួយការពេទ្យចិត្តសាស្ត្រ និងអ្នកហាត់ការ MFP ក៏អាចផ្តល់សេវាកម្មបានផងដែរ ប្រសិនបើការផ្តល់សេវាកម្មស្ថិតក្រោមការមើលខុសត្រូវរបស់បុគ្គលិកគ្លីនិក[8] ។

---

[6] 42 USC § 1396d(r)(5); 22 CCR §§ 51340 និង 51340.1 “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

[7] APL 17-018 p. វគ្គទី 7 "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[8] See: សៀវភៅសម្រាប់អ្នកផ្តល់សេវាកម្ម Medi-Cal រួចទាញចុះក្រោមទៅកាន់សេវាកម្មជម្ងឺវិកលចរិក (psychol) ។ ជាការប្រសើរបើអ្នកបើកឯកសារ zip ។ “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

## តើខ្ញុំអាចទទួលបានអ្វីផ្សេងទៀតពីផែនការថែទាំសុខភាព ដែលមានការចាត់ចែងរបស់ខ្ញុំ?

អ្នកអាចទទួលបាន ៖

- ការពិនិត្យសុខភាពផ្លូវចិត្ត
- ទទួលការបញ្ជូនទៅកាន់ និងមានការសម្របសម្រួលការថែទាំជាមួយនឹងផែនការថែទាំសុខភាពផ្លូវចិត្ត
- ការគ្រប់គ្រងសំណុំរឿងជម្ងឺ ។

## តើត្រូវធ្វើដូចម្តេចប្រសិនបើផែនការថែទាំសុខភាពដែលមានការចាត់ចែងរបស់ខ្ញុំបដិសេធ កាត់បន្ថយ ឬផ្អាច់សេវាកម្មចំពោះខ្ញុំ?

ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2017 បទបញ្ញត្តិថ្មីៗរបស់រដ្ឋាភិបាលសហព័ន្ធបានចូលជាធរមាន ដែលប្រាប់ពីរបៀបប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ផែនការថែទាំសុខភាពដែលមានការចាត់ចែង និង/ឬ ផ្តល់ពត៍មានអំពីបញ្ហាផ្សេងទៀតដល់ផែនការថែទាំសុខភាពដែលមានការចាត់ចែង តាមរយៈបណ្តឹងសារទុក្ខ ។

DHCS បានចេញលិខិតរបស់ផែនការទាំងអស់ (APL, All Plan Letter) 17-006 ចំពោះទម្រង់ការថ្មីៗទាំងអស់នេះ ។

សូមអានផងដែរអំពី “ការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែងរបស់ DRC ៖ ការប្តឹងឧទ្ធរណ៍ និងបណ្តឹងសារទុក្ខនៅឯ”

## ធនធានផ្សេងទៀត ៖

“កម្មវិធីច្បាប់សុខភាពជាតិ”

យើងខ្ញុំចង់ស្តាប់យោបល់អ្នក! សូមជួយបំពេញសំណួរសម្រង់មតិខាងក្រោម ស្តីអំពីការបោះពុម្ពផ្សាយរបស់យើងខ្ញុំ
ហើយប្រាប់ឲ្យយើងខ្ញុំបាននឹងពីគុណភាពការងាររបស់យើងខ្ញុំ!
[ចាប់ផ្តើមបំពេញសំណួរសម្រង់មតិ]

សម្រាប់ជំនួយផ្លូវច្បាប់ សូមហៅមកលេខ 800-776-5746 ឬបំពេញ បែបបទស្នើសុំជំនួយ ។ សម្រាប់គោលបំណងផ្សេងៗទៀត សូមហៅទូរស័ព្ទមកលេខ 916-504-5800 (កាលីហ្វ័រនីញ៉ាខាងជើង) 213-213-8000 (កាលីហ្វ័រនីញ៉ាខាងត្បូង) ។

Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html ។